ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ..០១៣៤...ក.ក៧៥

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការពារជាតិ
# ស្តីពី
# ការចាក់វ៉ាក់សាំងបង្ការជម្ងឺកូវីដ-១៩

អនុវត្តតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការដឹកនាំផ្ទាល់របស់ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រុមវ៉ាក់សាំងកូវីដ១៩ ក្រសួងការពារជាតិ ចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងSARS-Cov-2 "Sinopharm" ជូនចំពោះឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ប្រធានស្ថាប័នចំណុះក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ដែលមានអាយុចាប់ពី១៨ឆ្នាំ រហូតដល់អាយុលើសពី៥៩ឆ្នាំ តាមការស្ម័គ្រចិត្ត។

ពេលវេលានឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង១៤:០០នាទី នៅមន្ទីរពេទ្យព្រះកេតុមាលា។ ដោយឡែក ការចាក់វ៉ាក់សាំងSARS-Cov-2 "Sinopharm" ជូនចំពោះនាយទាហាន នាយទាហានរង និងពលទាហាន តាមស្ថាប័ន កងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ ក្រុមវ៉ាក់សាំងកូវីដ១៩ ក្រសួងការពារជាតិ នឹងជូនដំណឹងពីកាលបរិច្ឆេទ និងទីតាំងជាក់លាក់នៅពេលក្រោយ។

ក្នុងនាមក្រុមវ៉ាក់សាំងកូវីដ១៩ ក្រសួងការពារជាតិ សូមអញ្ជើញថ្នាក់ដឹកនាំ នាយទាហាន នាយទាហាន-រង និងពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្តនេះ ដើម្បីគាំទ្រគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការការពារសុខភាព និងលើកកម្ពស់សុខមាលភាពរបស់កងទ័ពយើង។

ថ្ងៃអង្គារ ១២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១
**រដ្ឋលេខាធិការប្រចាំការ ក្រសួងការពារជាតិ**
**និងជាប្រធានក្រុមវ៉ាក់សាំងកូវីដ១៩ កពជ**

នាយឧត្តមសេនីយ៍.**នាង_ផាត**

វិថីហ្សកនីមិត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៨ អ៊ីមែល៖ generalsec@mod.gov.kh